# ស្វែងយល់អំពីសញ្ញាទាំងឡាយនៃជំងឺអុតស្វា

## រោគសញ្ញាសំខាន់

**កន្ទួលរមាស់**



កន្ទួលរមាស់នេះ អាចៈ

- មើលទៅដូចជាឡើង ដុំពក មុន (លើស្បែក) ពងបែក ដំបៅ ឬមានឡើងក្រមរ
- ចេញនៅគ្រប់ទីកន្លែងនៅលើរាងកាយ រួមទាំងនៅលើប្រដាប់ភេទ ទ្វារធំ មាត់ ដៃ និងមុខផងដែរ
- ចេញនៅក្នុងកន្លែងតែមួយ ឬអាចរាលដាលពាសពេញរាងកាយ
- អាចមានការរមាស់ ឬឈឺចាប់ (ជាពិសេសប្រសិនបើកើតមាននៅក្នុងមាត់ ឬទ្វារធំ)

## រោគសញ្ញាផ្សេងទៀត

**រោគសញ្ញាដែលដូចគ្នាទៅនឹងជំងឺផ្តាសាយធំ (flu)**



គ្រុនក្តៅ/គ្រុនរងា



អស់កម្លាំង ឈឺសាច់ដុំ និងឈឺក្បាល



ហើមកូនកណ្តុរ

- រោគសញ្ញាដែលដូចគ្នាទៅនឹងជំងឺផ្តាសាយធំទាំងឡាយអាចលេចឡើងក្នុងចន្លោះពេល 1 ទៅ 4 ថ្ងៃមុនពេលកន្ទួលរមាស់ចាប់ផ្តើមកើតមាន ឬក្រោយពេលកន្ទួលរមាស់កើតមានហើយ
- មិនមែនមនុស្សគ្រប់គ្នានឹងមានរោគសញ្ញាទាំងនេះទេ

**ជាទូទៅ រោគសញ្ញានានាចាប់ផ្តើមកើតមានឡើងក្នុងចន្លោះពេល 5 ទៅ 21 ថ្ងៃបន្ទាប់ពីបានប៉ះពាល់ទៅនឹងមេរោគរួច**

កន្ទួលរមាស់អាចនឹងលេចឡើងក្នុងរូបរាងខុសៗគ្នា - សូមមើលខាងក្រោម។ កំណត់សម្គាល់៖ កន្ទួលរមាស់អាចនឹងមានភាពខុសគ្នាពីគំរូឧទាហរណ៍ទាំងនេះ។













**សូមទាក់ទងទៅគ្រូពេទ្យរបស់អ្នកភ្លាមៗ** ប្រសិនបើអ្នកមានកន្ទួលរមាស់ ឬដំបៅថ្មី ដែលខុសប្រក្រតី នៅលើផ្នែកណាមួយនៃរាងកាយរបស់អ្នក។ ការធ្វើបែបនេះមានសារៈសំខាន់ជាពិសេសប្រសិនបើអ្នកបានប៉ះពាល់ទៅនឹងនរណាម្នាក់ដែលមានជំងឺ ឬសង្ស័យថាមានជំងឺអុតស្វា។

រហូតដល់ពេលដែលអ្នកដឹងថាអ្នកមិនមានជំងឺអុតស្វាទេនោះ សូមអនុវត្តតាមវិធានការណ៍ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគ រួមមានទាំងការគ្របដណ្តប់កន្ទួលរមាស់របស់អ្នក និងការស្ថិតនៅឆ្ងាយពីអ្នកដទៃ។ សូមមើលគេហទំព័រ ph.lacounty.gov/monkeypoxisolation។

**ប្រសិនបើអ្នកមិនមានគ្រូពេទ្យប្រចាំខ្លួនទេ៖**

- សូមទូរស័ព្ទទៅនាយកដ្ឋានសុខភាពសាធារណៈ (Public Health) តាមរយៈលេខ 1-833-540-0473 (ដែលមានផ្តល់សេវាកម្មជូន 7 ថ្ងៃក្នុងមួយសប្តាហ៍ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 8:30 យប់) ឬក៏
- សូមទៅកាន់ គ្លីនិកផ្នែកសុខភាពផ្លូវភេទរបស់សុខភាពសាធារណៈ មួយដែលនៅជិតអ្នក។

**សូមស្កេនកូដ QR នេះ ដើម្បីស្វែងរកទីតាំងមួយ**

**For more information on Monkeypox, visit:**
ph.lacounty.gov/Monkeypox

Know the Signs of Monkeypox 8/31/2022 (Cambodian)

County of Los Angeles Public Health